ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 06 / 2015
ម៉ោង (Time/Heure): 9:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E347/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកឯកសារថ្មីៗ ដាក់ក្នុងសំណុំរឿង ០០២/០២

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៥ ("សំណើសុំ") ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយក (១) ជំពូកទី ២ នៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ("របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស") ដែលមានចំណងជើងថា "៣០ ឆ្នាំ របស់ ហ៊ុន សែន អំពើហិង្សា ការបង្ក្រាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា" និង (២) ការសិក្សារបស់ Dmitry Mosyakov ("ការសិក្សា") ដែលមានចំណងជើងថា "ខ្មែរក្រហម និងវៀតណាមកុម្មុយនីស្ត៖ ប្រវត្តិទំនាក់ទំនង ដូចដែលត្រូវបានរៀបរាប់នៅក្នុងបណ្ណសារសូវៀត" ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០៤ (ឯកសារ E347 កថាខណ្ឌ ១-១៤)[1]។ មេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានថា ជំពូកទី ២ នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សមានភ័ស្តុតាងពាក់ព័ន្ធនឹងភូមិភាគបូព៌ានៃរបបកម្ពុជា

[1] ឯកសារទាំងនេះមានលេខយោង ERN ដូចតទៅនេះ៖ 01086002-01086074 និង 01085963-01086001។

ប្រជាធិបតេយ្យ ជាពិសេស ទាក់ទងនឹងការវិវឌ្ឍនៃរចនាសម្ព័ន្ធយោធា និងការបះបោររបស់ជនជាតិចាមនៅក្នុងឆ្នាំ ១៩៧៥ (ឯកសារ E347 កថាខណ្ឌ ៦)។ មេធាវីការពារក្តីសន្និដ្ឋានថា ការសិក្សា ដែលបានផ្អែកជាចម្បងលើបណ្ណសាររបស់សូវៀត បានតាមដានឡើងវិញទៅលើការវិវឌ្ឍនៃទំនាក់ទំនងរវាងបក្សកុម្មុយនីស្តវៀតណាម និង បក្សកុម្មុយនីស្តកម្ពុជា ហើយការសិក្សានេះពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធរវាងប្រទេសទាំងពីរនេះ ហើយជាពិសេសពាក់ព័ន្ធនឹងវិធានការនៃការកំណត់គោលដៅលើក្រុមជាក់លាក់ រួមទាំងវៀតណាមផងដែរ (ឯកសារ E347 កថាខណ្ឌ ៧, ៩)។ មេធាវីការពារក្តីបានសន្និដ្ឋានបន្ថែមទៀតថា ការសិក្សានេះផ្តល់នូវការវិភាគអំពីជម្លោះប្រដាប់អាវុធដោយផ្អែកទៅលើការយល់ឃើញរបស់មន្ត្រីវៀតណាម ដែលជាការយល់ឃើញមួយដែលមិនមាននៅក្នុងកំណត់ត្រា ហើយមានការពាក់ព័ន្ធដោយហេតុថា វៀតណាម មិនដែលបានឆ្លើយតបទៅនឹងសំណើជាច្រើនដងរបស់សហចៅក្រមស៊ើបអង្កេត ដែលបានស្នើសុំការសហការឡើយ (ឯកសារ E347 កថាខណ្ឌ ១០-១១)។ ជាចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានថា របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងការសិក្សានេះ ជាភ័ស្តុតាងដោះបន្ទុក ជាឯកសារខ្លី និងអាចបកប្រែក្នុងរយៈពេលសមស្របបាន (ឯកសារ E347 កថាខណ្ឌ ១២-១៣)។ គ្មានភាគីណាមួយបានឆ្លើយតបទៅនឹងសំណើសុំនេះឡើយ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងថ្មីបាន ប្រសិនបើខ្លួនពិចារណាឃើញថា ភ័ស្តុតាងទាំងនោះមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះនឹងសម្រេចលើខ្លឹមសារនៃសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មីទាំងនេះ អនុលោមតាមល័ក្ខខ័ណ្ឌតម្រូវនៅក្នុងវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង តម្រូវថាគ្រប់ភាគីដែលបានស្នើសុំ ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬ ភ័ស្តុតាងដែលបានស្នើសុំនោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចរកបានបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដហើយក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះធ្លាប់បានទទួលយកភ័ស្តុតាងដែលមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវតឹងរ៉ឹងនេះផងដែរ រួមមាន ក្នុងករណីដែលភ័ស្តុតាងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងក្នុង

ករណីដែលភស្តុតាងដែលបានស្នើឡើងគឺជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ ក្នុងករណីដែលភាគីផ្សេងទៀតមិនជំទាស់ ទៅនឹងភស្តុតាងទាំងនេះ (ឯកសារ E276/2 កថាខណ្ឌ ២ យោងលើឯកសារ E190 និង ឯកសារ E172/24/5/1)។

*ជំពូកទី ២ នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស*

៣. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សត្រូវបាន បោះពុម្ពផ្សាយនៅក្នុងខែ មករា ឆ្នាំ ២០១៥ ហេតុដូច្នេះ គឺមិនអាចរកបាននៅមុនពេលចាប់ផ្តើម ការជំនុំជម្រះនៅក្នុងឆ្នាំ ២០១១ ឡើយ។ ដោយហេតុថា សំណើសុំឱ្យទទួលយកឯកសារនេះ ត្រូវបានដាក់ប្រហែលជាក្នុងរយៈពេល ៣ ខែ ក្រោយការបោះពុម្ពផ្សាយ អង្គជំនុំជម្រះចាត់ទុក ថា សំណើសុំនេះត្រូវបានដាក់ទាន់ពេលវេលាកំណត់។

៤. អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សមានចំណងជើង ថា "៣០ ឆ្នាំ របស់ ហ៊ុន សែន អំពើហិង្សា ការបង្ក្រាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា"។ របាយការណ៍នេះលើកឡើងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ផ្អែកលើការយល់ឃើញចង្អៀតមួយ ដែលមានសារប្រយោជន៍តិចតួចសម្រាប់គោលបំណងនៃការកំណត់អង្គហេតុ នៅក្នុងការជំនុំ-ជម្រះបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា របាយការណ៍អង្គការឃ្លាំ មើលសិទ្ធិមនុស្ស ហាក់ដូចជារបាយការណ៍សង្ខេបចេញពីប្រភពជាច្រើនខុសៗគ្នាដែលបាន យោងនៅក្នុងនោះ ហើយមិនមែនជារបាយការណ៍វាយតម្លៃលើប្រភពដែលបានលើកឡើងនោះ ឡើយ។ ទម្រង់របាយការណ៍នេះតម្រូវឱ្យមានការពិនិត្យឱ្យបានហ្មត់ចត់លើសម្ភារៈឯកសារ ដែលបានយោង។ ទាក់ទងនឹងចំណុចនេះ អង្គជំនុំជម្រះសង្កេតឃើញថា ឯកសារយោងខ្លះមាន លក្ខណៈស្រពិចស្រពិលខ្លាំង ដូចជា "កិច្ចសម្ភាសន៍របស់អ្នកសារព័ត៌មានជាមួយនឹងអ្នក ស្រុក" និង "កិច្ចសម្ភាសន៍អង្គការមិនមែនរដ្ឋាភិបាល" ដោយមិនបានបញ្ជាក់អំពីបុគ្គលដែល ត្រូវបានសម្ភាសន៍នោះឡើយ (ឧទាហរណ៍ លេខយោងជើងទំព័រ ៥៥, ៧៥, ៨៨, ១០១, ១០៧, ១១៦; សូមមើលផងដែរ "យោងតាមមនុស្សម្នាក់ដែលរស់នៅក្នុងតំបន់ Chiro" ត្រង់ ទំព័រ ១៨)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ជំពូកទី ២ នៃរបាយការណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្ស មិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុដែលជាគោលដៅនៃការ

ស្នើសុំពិនិត្យភ័ស្តុតាង អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងឡើយ ហើយជំពូកនេះក៏មិនមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិតអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះដែរ។

*ការសិក្សា*

៥. ការសិក្សានេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០៤ ហេតុដូច្នេះ អាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះក្នុងឆ្នាំ ២០១១ ដូចដែលមេធាវីការពារក្តី ខៀវ សំផន បានអះអាង (ឯកសារ E347 កថាខណ្ឌ ៨)។ ទោះបីជាមេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានថា ពួកគាត់មិនបានដឹងនាពេលមុន អំពីការសិក្សានេះក៏ដោយ ប៉ុន្តែមេធាវីការពារក្តីមិនបានបង្ហាញអំពីមូលហេតុ ថាហេតុអ្វីបានជាឯកសារនេះមិនត្រូវបានរកឃើញ ទោះបីជាបានបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដហើយក៏ដោយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំឱ្យទទួលយកការសិក្សានេះមិនត្រូវបានដាក់ទាន់ពេលកំណត់ឡើយ។

៦. ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា វាជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការទទួលយកការសិក្សានេះ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អ្នកនិពន្ធ Dmitry Mosyakov គឺជាអ្នកសិក្សាស្រាវជ្រាវម្នាក់ដែលមានជំនាញលើប្រធានបទនៃការសិក្សានេះ ដោយសារថា លោកគឺជាសាស្ត្រាចារ្យម្នាក់ និងជាប្រធានមជ្ឈមណ្ឌលទទួលបន្ទុកការសិក្សាស្រាវជ្រាវលើតំបន់អាស៊ីអាគ្នេយ៍ អូស្ត្រាលី និងអូសេអានីនៅវិទ្យាស្ថានអូរៀនថលស្តាឌីស៍ (Institute of Oriental Studies) ក្នុងរដ្ឋបណ្ឌិតសភាវិទ្យាសាស្ត្ររុស្ស៊ី (Russian Academy of Sciences)។ *តាមការយល់ឃើញជាបឋម* ការសិក្សានេះមានភាពពាក់ព័ន្ធដោយសារការសិក្សានេះលើកឡើងអំពីបញ្ហាផ្សេងៗ ដែលក្នុងនោះរួមមាន ជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ព្រមទាំងសាវតារប្រវត្តិសាស្ត្រផងដែរ (ដីកាដំណោះស្រាយ កថាខណ្ឌ ១៨-២០, ២៣, ១៥០-១៥៥)។ ការសិក្សានេះអាចយកមកវាយតម្លៃរួមជាមួយនឹងឯកសារផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងរួចហើយ ហើយដែលពាក់ព័ន្ធនឹងបញ្ហាតែមួយ។ លើសពីនេះទៀត គ្មានភាគីណាមួយបានជំទាស់ទៅនឹងការទទួលយកឯកសារមួយនេះនោះទេ។ ហេតុដូច្នេះ ឯកសារមួយនេះបានបំពេញលក្ខខ័ណ្ឌតម្រូវដែលមានចែងនៅក្នុងវិធាន ៨៧(៣)

នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះយល់ឃើញថា ឯកសារនេះមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិតអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន មួយផ្នែក។ អង្គជំនុំជម្រះសម្រេចទទួលយកការសិក្សាជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះបដិសេធមិនទទួលយក ជំពូកទី ២ នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សឡើយ។

៨. អនុស្សរណៈនេះចាត់ទុកថាជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E347។